EDU/MAN-280

Sophel

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កម្មវិធីសិលា

# បទពិសោធន៍នៃការអនុវត្តន៍គំរោង
# ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

## ខេត្តពោធិសាត់

ខែវិច្ឆិកា ឆ្នាំ២០០២

រៀបចំដោយ : លឹម ហាំងគ្រី. ទីប្រឹក្សាកសិកម្មប្រចាំខេត្តពោធិសាត់
: ក្រុមសំរបសំរួលបច្ចេកទេសនៃការគ្រប់គងធនធានធម្មជាតិ និងបរិស្ថាន



library.ncdd.gov.kh
006160

បណ្ណាល័យ
គ.ជ.អ.ប

# មាតិកាអត្ថបទ


១. ការពិភាក្សា និងរៀបចំគំរោងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ១

២. សមាសភាពក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ១

២.១. ក្រុមសំរបសំរួលបច្ចេកទេសនៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NREM-TFT) ១

២.២. ជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានខេត្ត ២

២.៣. អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិក្នុងខេត្តដែលបានចូលរួម ៣

២.៤. ក្រុមសំរបសំរួលស្រុកផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ៣

២.៥. ជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថានរបស់ គប្រ នៃ គអជខ ៤

៣. វចនាសម្ព័ន្ធនៃការអនុវត្តន៍គំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ៥

៤. ការរៀបចំក្រុម NREM ៦

៤.១. ចក្ខុវិស័យរបស់ក្រុម ៦

៤.២. បេសកកម្មរបស់ក្រុម ៦

៤.៣. គោលដៅរបស់ក្រុម ៦

៤.៤. ទិសដៅរបស់ក្រុម ៦

៤.៥. គោលការណ៍របស់ក្រុម ៧

៥. ការកសាងសមត្ថភាពរបស់ក្រុម NREM ៧

៥.១. ការបណ្ដុះបណ្ដាលវគ្គទី១អំពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងធនធានធម្មជាតិ ៧

៥.២. ការបណ្ដុះបណ្ដាលអំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ៨

៥.៣. ទស្សនៈកិច្ចសិក្សាអំពីការបញ្ជ្រាបឧបករណ៍កសាងផែនការធនធានធម្មជាតិ ទៅក្នុងដំណើរការកសាងផែនការមូលដ្ឋាន នៅខេត្តរតនគីរី ៩

៦. ដំណើរការនៃការបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NMTM) ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ៩

៦.១. ការប្រជុំពិភាក្សា ដើម្បីបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM ៩

៦.២. ការចុះដកស្រង់បទពិសោធន៍អំពីដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ ១១

៦.៣. ការប្រជុំដើម្បីកែសំរួល NMTM ឡើងវិញលើកទី១ ១១

៦.៤. ការប្រជុំដើម្បីកែសំរួល NMTM ឡើងវិញលើកទី២ ១២

៧. ឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NMTM) ១៣

៧.១. ផែនទីឃុំ (ភូមិ) ១៣

| | | |
|---|---|---|
| ៧.២. | ការវិភាគស្ថានភាពធនធានធម្មជាតិ (ផ្សាក្រោម និងនិន្នាការ) | ១៤ |
| ៧.៣. | សំណួរគន្លឹះ ឬសំណួរសំខាន់ៗ | ១៥ |
| ៧.៤. | តំរូវការពេលវេលា ក្នុងការអនុវត្តឧបករណ៍បញ្ញាប NREM | ២១ |
| ៨. | ការរៀបចំសំរាប់ការអនុវត្ត | ២១ |
| ៨.១. | សំណើបែងចែកការងារ នៅក្នុងការសំរបសំរួលការកសាងផែនការអភិវឌ្ឍន៍ឃុំ | ២១ |
| ៨.២. | ការបែងចែកឃុំគោលដៅ | ២២ |
| ៩. | ការបណ្តុះបណ្តាលអំពី NMTM ដល់ក្រុមសំរបសំរួលខេត្ត-ស្រុក ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ | ២២ |
| ១០. | លទ្ធផលនៃការអនុវត្ត NMTM នៅឃុំគោលដៅទាំង៦ | ២៣ |
| ១០.១. | ការសំរបសំរួលរបស់ក្រុម NREM-TFT | ២៣ |
| ១០.២. | ការកែសំរួលផែនទីឃុំ (ភូមិ) | ២៤ |
| ១០.៣. | ការវិភាគស្ថានភាពធនធានធម្មជាតិ | ២៤ |
| ១០.៤ | បញ្ហា/តំរូវការជាអាទិភាពរបស់ឃុំ | ២៨ |
| ១០.៥ | ការធ្វើអាទិភាពឃុំគោលដៅទាំង៦ សំរាប់អនុវត្តនៅឆ្នាំ២០០៣ | ២៨ |
| ១១. | ការទំនាក់ទំនងនៅក្នុងបណ្តាញការងារនៃការគ្រប់គ្រងធនធានធម្មជាតិ | ២៨ |
| ១២. | ការចូលរួមរបស់គណៈកម្មាធិការប្រតិបត្តិខេត្តពោធិសាត់ | ២៩ |
| ១៣. | ការចូលរួមរបស់ក្រុមទីប្រឹក្សាធនធានធម្មជាតិ-បរិស្ថានថ្នាក់ជាតិ និង PLG/STF ភ្នំពេញ | ១៩ |

## បទពិសោធន៍នៃការអនុវត្តគំរោង
## គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

### ១ ការពិភាក្សា និងរៀបចំគំរោងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

គំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន របស់ខេត្តពោធិសាត់ ត្រូវបានរៀបចំឡើង ដោយស្របតាមយុទ្ធសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាននៃកម្មវិធីសិលា (២០០២-២០០៥) និងគំរោងបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (២០០៣-ខែមិថុនា ២០០៤) ដែលគាំទ្រដោយ ដានីដា ។

ដំណើរការនៃការរៀបចំគំរោងនេះ មានដូចខាងក្រោម :

- ការពិភាក្សាជាមួយខេត្តរតនគិរី និង PLG/STF ភ្នំពេញ ។
- ការពិភាក្សានៅតាមមន្ទីរជំនាញដោយឡែក១ពីគ្នា ។
- ការប្រជុំពិភាក្សារួមគ្នារវាងមន្ទីរពាក់ព័ន្ធក្នុងខេត្តនានា ។
- ការប្រជុំពិភាក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិពាក់ព័ន្ធក្នុងខេត្តនានា ។
- ការប្រជុំពិភាក្សារបស់ គប្រ នៃ គអជខ ពោធិសាត់ ។

គំរោងនេះ ត្រូវបានពិភាក្សា និងរៀបចំ ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០២ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ (ថ្ងៃចុះហត្ថលេខា) ។

ឧបសម្ព័ន្ធទី១ : ឯកសារកិច្ចសន្យាការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។

### ២ សមាសភាពរបស់ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

#### ២.១ ក្រុមសំរបសំរួលបច្ចេកទេសនៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NREM-TFT)

ដំណើរការនៃការជ្រើសរើសក្រុម NREM-TFT ត្រូវបានពិភាក្សា នៅក្នុងការប្រជុំ គប្រ នៃ គអជខ ។ អង្គប្រជុំបានសំរេចក្នុងការជ្រើសរើស ដូចខាងក្រោម :

ក). ប្រធានក្រុម :

ប្រធានក្រុម NREM-TFT ត្រូវបានជ្រើសតាំង ដោយផ្អែកលើសមត្ថភាព លទ្ធភាពពេលវេលា និងតំរូវការចាំបាច់ ។

ខ). សមាជិកក្រុមចំនួន៦នាក់ :

- មន្ទីរពាក់ព័ន្ធទាំង៤ ត្រូវបញ្ជូនឈ្មោះមន្ត្រីដោយភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេប ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យនៃក្រុម NREM-TFT (ដូចមាននៅក្នុងឯកសារកិច្ចសន្យា) ។

- ក្រុមពិនិត្យប្រវត្តិរូបសង្ខេបរបស់បេក្ខជន រួមមានសមាជិក គប្រ នៃ គអជខ ចំនួន២រូប ប្រធានក្រុម NREM-TFT ១រូប និងបុគ្គលិក PLG ប្រចាំខេត្តពោធិសាត់១រូប ។ ក្រុមនេះ មានភារៈកិច្ច២សំខាន់ :

  ១). ធ្វើការពិនិត្យ និងវាយតំលៃទៅលើប្រវត្តិសង្ខេបរបស់បេក្ខជន ។ ក្នុងករណី បេក្ខជនណាដែលមិនបានបំពេញទៅនឹងលក្ខណៈវិនិច្ឆ័យ ត្រូវបញ្ជូនឈ្មោះបេក្ខជនទាំងនេះ ទៅមន្ទីរសាមី ហើយស្នើអោយមន្ទីរសាមីធ្វើបញ្ជូនឈ្មោះបេក្ខជនមកជាថ្មី ។

  ២). ធ្វើការសង្ខេបលទ្ធផលនៃការពិនិត្យនិងវាយតំលៃនេះ ហើយរៀបចំដីកា ដាក់ជូនឯកឧត្តមអភិបាលខេត្ត និងជាប្រធាន គប្រ នៃ គអជខ ដើម្បីពិនិត្យ និងសំរេច ។

មូលហេតុចំបងក្នុងការសំរេចធ្វើការជ្រើសរើសក្រុម ដោយមិនធ្វើការផ្សព្វផ្សាយទូទៅ និងសំភាសន៍បែបនេះ គឺដោយសារក្រុមពុំមានប្រាក់ឧបត្ថម្ភប្រចាំខែទេ ។ ប្រសិនបើក្រុមនេះទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ការជ្រើសរើស នឹងត្រូវបានអនុវត្តទៅតាមនីតិវិធីនៃការជ្រើសរើសបុគ្គលិករបស់កម្មវិធីសិលា ។

ខាងក្រោមនេះ គឺជាសមាភាពនៃក្រុម NREM-TFT :

| លរ | ឈ្មោះ | ភេទ | អង្គភាព | តួនាទីក្នុងក្រុម |
|---|---|---|---|---|
| ១ | ថន គីម ហុង | ប្រុស | មន្ទីរបរិស្ថាន | ប្រធានក្រុម |
| ២ | សួន ច័ន្ទឌី | ប្រុស | មន្ទីរបរិស្ថាន | សមាជិកក្រុម |
| ៣ | ជ័យ ចន្ទី | ស្រី | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកក្រុម |
| ៤ | ភុំ ថាយ | ប្រុស | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកក្រុម |
| ៥ | អ៊ឹម សុភី | ប្រុស | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកក្រុម |
| ៦ | មាស ប៊ុនធឿន | ប្រុស | មន្ទីរធនធានទឹក និងឧតុនិយម | សមាជិកក្រុម |
| ៧ | ជុំ សាវ៉ាល់ | ប្រុស | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិកក្រុម |

## ២.២ ជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានខេត្ត

ជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានខេត្ត ត្រូវបានចាត់តាំង និងបញ្ជូនមកដោយមន្ទីរសាមី នៅពេលមន្ទីរទាំងនេះ បានទទួលលិខិតអញ្ជើញរបស់ គប្រ នៃ គអជខ ។

| លរ | ឈ្មោះ | ភេទ | អង្គភាព | តួនាទី |
|---|---|---|---|---|
| ១ | សេង ហុង | ប្រុស | មន្ទីរទេសចរណ៍ខេត្ត | អនុប្រធានមន្ទីរ |
| ២ | សុខ គង់ | ប្រុស | មន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត | អនុប្រធានមន្ទីរ |
| ៣ | ស៊ឹម សារឿន | ប្រុស | មន្ទីរឧស្សាហកម្មខេត្ត | អនុប្រធានការិយាល័យ |
| ៤ | គាន់ ចរិយា | ស្រី | មន្ទីរផែនការខេត្ត | មន្ត្រីស្ថិតិ |

**តួនាទី និងភារៈកិច្ច ៖**

- ចូលរួមក្នុងការបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្រ្ជាប NREM និងជំហានអនុវត្តលំអិតនៃផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ។
- ចូលរួមក្នុងការអនុវត្តន៍ ឧបករណ៍ និងវិធីសាស្ត្របញ្រ្ជាប NREM នៅក្នុងភូមិគោលដៅរបស់ខ្លួន ។
- ផ្តល់យោបល់ក្នុងក្របខ័ណ្ឌបច្ចេកទេសដែលទាក់ទងទៅនឹងវិស័យរបស់ខ្លួន ។
- ចូលរួមក្នុងការប្រជុំ បណ្តុះបណ្តាល សិក្ខាសាលា ទស្សនៈកិច្ចសិក្សា និងព្រឹត្តិការណ៍នានាដែលទាក់ទងទៅនឹង NREM ។

## ២.៣ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិក្នុងខេត្ត ដែលបានចូលរួម

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបានចូលរួម គំរោងសាកល្បងនៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននេះ ត្រូវបានចាត់តាំង និងបញ្ជូនមកដោយ អង្គការសាមី នៅពេលអង្គការទាំងនេះបានទទួលលិខិតអញ្ជើញរបស់ គប្រ នៃ គអជខ ។

| លរ | ឈ្មោះ | ភេទ | អង្គភាព | តួនាទី |
|---|---|---|---|---|
| ១ | ហឿន ហុន្នី | ប្រុស | អង្គការ CFDS | បុគ្គលិក |
| ២ | ព្រំ អ៊ុត | ប្រុស | អង្គការ EPDO | នាយក |
| ៣ | ទូច សារឿន | ប្រុស | អង្គការ BDASE | នាយករង |
| ៤ | ស៊ុន ផល្លា | ប្រុស | អង្គការ Concern Worldwide | បុគ្គលិក |

**តួនាទី និងភារៈកិច្ច ៖**

- ចូលរួមក្នុងការបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្រ្ជាប NREM និងជំហានអនុវត្តលំអិតនៃផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ។
- ធ្វើការអនុវត្តន៍ឧបករណ៍ និងវិធីសាស្ត្របញ្រ្ជាប NREM និងជំហានអនុវត្តលំអិតនៃផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម នៅក្នុងភូមិគោលដៅរបស់ខ្លួន ។
- ផ្លាស់ប្តូរបទពិសោធន៍ និងផ្តល់យោបល់ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។
- ចូលរួមក្នុងការប្រជុំ បណ្តុះបណ្តាល សិក្ខាសាលា ទស្សនៈកិច្ចសិក្សា និងព្រឹត្តិការណ៍នានាដែលទាក់ទងទៅនឹង NREM ។

## ២.៤ ក្រុមសំរបសំរួលស្រុក ផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

បន្ទាប់ពីបានចុះធ្វើការវាយតំលៃគំរោង **"ការបញ្រ្ជាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៅក្នុងកម្មវិធីសិលា ២០០៣-មិថុនា ២០០៤"** ក្រុមបេសកកម្មជានីដា បានស្នើ

សុំអោយបង្កើតក្រុមសំរបសំរួលស្រុកផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានចំនួន៣រូប ដែលនឹងជ្រើសរើសចេញពីមន្ត្រីផ្សព្វផ្សាយកសិកម្ម ដើម្បីអនុវត្តគំរោងសាកល្បងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានក្នុងនាមជាអ្នកសំរបសំរួលថ្នាក់ស្រុក ។ ក្រុមនេះ មិនត្រូវបានបង្កើតឡើងទេ ដោយសារមិនមានថវិកាគ្រប់គ្រាន់សំរាប់ឧបត្ថមក្រុម ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រុមសំរបសំរួលបច្ចេកទេសថ្នាក់ស្រុក នៃគំរោងអភិវឌ្ឍន៏កសិកម្មគាំទ្រដល់កម្មវិធីសិលា (DTST-ADESS) ត្រូវបានដាក់ជំនួសក្រុមនេះ តាមរយៈការពិភាក្សា និងព្រមព្រៀងរវាងគណ:កម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា PLG-ភ្នំពេញ PSU/MAFF គប្រ នៃ គអជខ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ។

ក្រុម DTST-ADESS ក្នុងនាមជាទីប្រឹក្សា នឹងចូលរួមជាមួយនឹងក្រុម NREM-TFT នៅក្នុងការកសាងផែនការអភិវឌ្ឍន៏ឃុំ នៅជំហានទី១ និងជំហានទី២។

## ២.៥ ជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន របស់ គប្រ នៃ គអជខ

ដោយសារមានតំរូវការចាំបាច់ ដើម្បីអោយដំណើរនៃការអនុវត្តន៏គំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន អោយកាន់តែមានភាពប្រសើរឡើងថែមទៀត គប្រ នៃ គអជខ បានសំរេចជ្រើសរើសសមាជិក គប្រ នៃ គអជខ មួយរូប ជាជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។

លោក ទិត សំអឿន ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ត្រូវបានជ្រើសតាំងជាជនបង្គោលផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន របស់ គប្រ នៃ គអជខ ។

**តួនាទី និងភារៈកិច្ច**

- ផ្តល់ប្រឹក្សា ដល់ក្រុម NREM-TFT ក្នុងការគ្រប់គ្រងគំរោងគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន។
- ធ្វើបច្ចុប្បន្នភាព នូវការរីកចំរើនរបស់គំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជូនអង្គប្រជុំ គ.ប្រ ហើយជាពិសេស ឯកឧត្តម អភិបាលខេត្ត និងជាប្រធាន គប្រ នៃ គអជខ ។
- តំណាងអោយឯកឧត្តមអភិបាលខេត្ត និងជាប្រធាន គប្រ នៃ គអជខ ធ្វើការបង្ហាញអំពីការរីកចំរើនរបស់គំរោងគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន ដល់ម្ចាស់អំណោយ និងក្រុមបេសកកម្មនានា។
- ធានាអោយបានប្រាកដថា យុទ្ធសាស្ត្រអនុវត្តនៃគំរោងគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន ត្រូវបានអនុវត្តស្របទៅតាម : ក).គោលនយោបាយរាជរដ្ឋាភិបាល ស្តីអំពីការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និង ខ).យុទ្ធសាស្ត្របញ្រ្ជាបការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន នៃកម្មវិធីសិលា (២០០២-២០០៥) ។
- ធានាអោយបានប្រាកដថា សកម្មភាពរបស់គំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាព ។
- សំរបសំរួលការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជាមួយមន្ទីរពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ

និងអង្គការមិនមែនរដ្ឋាភិបាលនានា ។

- ចូលរួមការប្រជុំ សិក្ខាសាលា សន្និសិទ ទស្សនៈកិច្ចសិក្សា និងព្រឹត្តិការណ៍នានា ស្តីអំពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។

ដើម្បីអោយមន្ត្រីពាក់ព័ន្ធបំពេញការងារពេញលេញ និងដើម្បីអោយការប្រតិបត្តិរបស់គំរោងប្រព្រឹត្តទៅតាមនីតិវិធីរដ្ឋបាល ដីកាចំនួន៣ សេចក្តីណែនាំចំនួន១ និងកិច្ចសន្យាជួលទោចក្រយានយន្ត ត្រូវបានរៀបចំឡើង ។

ឧបសម្ព័ន្ធទី២ : ២.ក). ដីកាស្តីពីការតែងតាំងក្រុម NREM-TFT ។

២.ខ). ដីកាស្តីពីការតែងតាំងមន្ត្រីអនុម័ត និងពិនិត្យបញ្ជាក់ សំរាប់គាំទ្រក្រុម NREM-TFT ។

២.គ). សេចក្តីណែនាំស្តីពីការគាំទ្រក្រុម NREM-TFT ។

២.ឃ). ដីកាស្តីពីការតែងតាំងជនបង្គោល NREM របស់ គប្រ ។

២.ង). កិច្ចសន្យាជួលទោចក្រយានយន្ត ។

## ៣ រចនាសម្ព័ន្ធនៃការអនុវត្តគំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន



## ៤ ការរៀបចំក្រុម NREM (NREM Group Organizing)

ដើម្បីអោយមានគោលដៅច្បាស់លាស់ ក្នុងការបំពេញការងារ ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន បានពិភាក្សា និងបង្កើត ចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅ និងគោលការណ៍ របស់ខ្លួន ។

### ៤.១ ចក្ខុវិស័យរបស់ក្រុម

ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានមួយ របស់ខេត្តពោធិសាត់ ដែលប្រកបដោយសមត្ថភាព ការប្តេជ្ញាចិត្ត និងសាមគ្គីភាព មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការជួយដល់សហគមន៍ និងភាគីពាក់ព័ន្ធ ដើម្បីប្រើប្រាស់ អភិវឌ្ឍន៍ និងគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តភាព ។ ក្រុម មានលទ្ធភាព ក្នុងការផ្តល់សេវាកម្មបណ្តុះបណ្តាល និងប្រឹក្សា អំពីការងារគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៅក្នុងខេត្ត និងក្រៅខេត្ត ។

### ៤.២ បេសកកម្មរបស់ក្រុម

- បញ្ជ្រាបការងារគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។
- ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ និង គ.ផ.ថ អំពីផែនការអភិវឌ្ឍន៍ឃុំ ដែលបានបញ្ចូលនូវឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការងារគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។
- ផ្សព្វផ្សាយចំណេះដឹងនានា ដែលទាក់ទងទៅនឹងការងារគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។
- ជួយដល់សហគមន៍ គប្រ និងភាគីពាក់ព័ន្ធ ក្នុងការអនុវត្តន៍គំរោង ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។

### ៤.៣ គោលដៅរបស់ក្រុម

នៅឆ្នាំ២០០៤ ក្រុម មានរចនាសម្ព័ន្ធការងារច្បាស់លាស់ និងមានចំណេះដឹងអំពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ដើម្បីជួយដល់សហគមន៍ និងភាគីពាក់ព័ន្ធ ក្នុងកិច្ចអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តភាព នៅក្នុងឃុំគោលដៅចំនួន៦ នៃខេត្តពោធិសាត់ ។

### ៤.៤ ទិសដៅរបស់ក្រុម

នៅដំណាច់ឆ្នាំ២០០២ ក្រុមមាន :

- ចំណេះដឹងអំពីមូលដ្ឋានគ្រឹះ នៃការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ។
- ចំណេះដឹងអំពីផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ។
- លទ្ធភាពបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ។
- លទ្ធភាពបង្កើតជំហានអនុវត្តផែនការប្រើប្រាស់ដីធ្លីលំអិត របស់ខេត្តពោធិសាត់ ។
- លទ្ធភាពជួយដល់ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ ក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ ដែលបានបញ្ចូលនូវឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការងារគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។

### ៤.៥ គោលការណ៍របស់ក្រុម

- គោរព និងយោគយល់គ្នាទៅវិញទៅមក ។
- សមភាព និងសមធម៌ក្នុងក្រុម ។
- សាមគ្គីភាពក្នុងក្រុម ។
- ភាពស្មោះត្រង់ និងតម្លាភាព។
- ជឿជាក់គ្នាទៅវិញទៅមក ។
- គោរពទៅតាមការសំរេចចិត្តរបស់សហគមន៍ ។
- គោរពតាមមតិភាគច្រើនក្នុងក្រុម ។
- ធ្វើការងារ ទៅតាមផែនការងារ ។ លទ្ធផល ឬបទពិសោធន៍នៃការធ្វើការងារ ត្រូវបានចងក្រង និងរក្សា/គ្រប់គ្រង អោយបានត្រឹមត្រូវ ។

## ៥ ការកសាងសមត្ថភាពក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

### ៥.១ ការបណ្តុះបណ្តាលវគ្គទី១អំពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងធនធានធម្មជាតិ

ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន បានទទួលការបណ្តុះបណ្តាលវគ្គទី១ អំពី មូលដ្ឋានគ្រឹះ នៃការគ្រប់គ្រងធនធានធម្មជាតិ រយៈពេល៥ថ្ងៃ ដែលក្នុងនោះ ៤ថ្ងៃសិក្សានៅក្នុងថ្នាក់ និង១ថ្ងៃលំហាត់អនុវត្តនៅតាមមូលដ្ឋាន ។ ការបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើង នៅថ្ងៃទី២៤-២៨ ខែមិថុនា ឆ្នាំ២០០២ និងបានគ្របដណ្តប់លើប្រធានបទដូចខាងក្រោម :

**ផ្នែកទី១ : ប្រព័ន្ធ និងវិធីសាស្ត្រជាប្រព័ន្ធ**

១.១ និយមន័យនៃប្រព័ន្ធ

១.២ ប្រព័ន្ធធម្មជាតិ និងវិធីសាស្ត្រទីជំរាល (Watershed) ។

- វដ្តនៃទឹក
- ទឹកក្រោមដី
- លំហូរនៃទឹកលើផ្ទៃដី
- កករ/ល្បាប់

១.៣ ប្រព័ន្ធជីវិតរស់នៅ ។

១.៤ អន្តរកម្មរវាងប្រព័ន្ធធម្មជាតិ និងប្រព័ន្ធជីវិតរស់នៅ ។

**ផ្នែកទី២ : ផលប៉ះពាល់ដែលបណ្តាលមកពីសកម្មភាពរបស់មនុស្ស**

២.១ ការប្រើប្រាស់សារធាតុគីមី ។

២.២ ការបំផ្លាញ/ការដកចេញនូវគំរបរុក្ខជាតិ ។

២.៣ កាកសំណល់ និងជីគីមី ក្នុងការធ្វើកសិកម្ម ។

២.៤ ការដាំដុះ ។

២.៥ ការសាងសង់លំនៅស្ថាន ។

២.៦ ការវិភាគនិន្នាការ ។

**ផ្នែកទី៣** : បទពិសោធន៍អំពីការគ្រប់គ្រងធនធានធម្មជាតិ នៅខេត្តរតនគីរី

**ផ្នែកទី៤** : បទពិសោធន៍អំពីការដាំឈើហូបផ្លែ និងស្មៅចំណីសត្វ តាមបែបប្រពលវប្បកម្ម របស់ **លោកគ្រេហ្គម គ្រោន** នៅប្រទេសអូស្ត្រាលី ។

**ផ្នែកទី៥** : បទពិសោធន៍អំពីការគ្រប់គ្រងធនធានធម្មជាតិ នៅវណ្ណណាហ្គាលេន សាធារណៈរដ្ឋឥណ្ឌា ។

ឧបសម្ព័ន្ធទី៣ : ៣.ក). ឯកសារបណ្តុះបណ្តាល

៣.ខ). របាយការណ៍កំណត់សំគាល់របស់គ្រូបណ្តុះបណ្តាល ។

៥.២ ការបណ្តុះបណ្តាលអំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

តាមផែនការ ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានបណ្តុះបណ្តាល អំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ជាមួយនឹងក្រុមសំរបសំរួលស្រុក-ខេត្ត និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ក៏ប៉ុន្តែករណីនេះ មិនអាចអនុវត្តន៍បានទេ ដោយសារចំនួនសិក្ខាកាមច្រើនពេក ។ម្យ៉ាងវិញទៀត ការបណ្តុះបណ្តាលដោយឡែក អំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ សំរាប់ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ក៏មិនអាចអនុវត្តន៍បានផងដែរ ដោយសារពេលវេលាមិនអំណោយផល ។

ដូចនេះ ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានណែនាំអំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់រយៈពេល១ថ្ងៃ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ ។

**អនុសាសន៍ :** ការបណ្តុះបណ្តាលអំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ គួរត្រូវបានធ្វើឡើងយ៉ាងពេញលេញ និងមានការអនុវត្តន៍ជាក់ស្តែងផង ។

ឧបសម្ព័ន្ធទី៤ : ឯកសារស្តីអំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។

៥.៣ ទស្សនៈកិច្ចសិក្សាអំពីការបញ្ជ្រាបឧបករណ៍កសាងផែនការធនធានធម្មជាតិ ទៅក្នុងដំណើរការកសាងផែនការមូលដ្ឋាន នៅខេត្តរតនគិរី

ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ចំនួន១៨នាក់ (ស្រី២នាក់) បានធ្វើទស្សនកិច្ចសិក្សារយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៥-១៩ ខែកក្កដា ឆ្នាំ២០០២ ទៅកាន់ខេត្តរតនគិរី ។ ក្នុងដំណើរទស្សនៈកិច្ចសិក្សានេះ ក្រុមបានសិក្សា (ពត៌មានមពិស្តារ សូមអានឧបសម្ព័ន្ធទី៥) :

- បទពិសោធន៍ក្នុងការគ្រប់គ្រង និងគាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិ ។
- ដំណើរការកសាងផែនការមូលដ្ឋានដែលបានសមាហរណកម្មជាមួយការគ្រប់គ្រងធនធានធម្មជាតិ ។
- ការអនុវត្តគំរោងគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ។
- ការអនុវត្តគំរោងដីធ្លី ។

ឧបសម្ព័ន្ធទី៥ : ៥.ក). សំណើទស្សនៈកិច្ចសិក្សា (Study Tour Proposal) ។

៥.ខ). របាយការណ៍ទស្សនៈកិច្ចសិក្សា ទៅកាន់ខេត្តរតនគិរី ។

## ៦ ដំណើរការនៃការបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

៦.១ ការប្រជុំពិភាក្សា ដើម្បីបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM

មុននឹងឈានទៅដល់ការពិភាក្សាអំពី ឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ក្រុមបានឯកភាពគ្នាទៅលើក្របខ័ណ្ឌនៃការពិភាក្សាដូចខាងក្រោម :

ក. ជំហាននៃផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ត្រូវបានរក្សាទាំងស្រុង ដោយគ្រាន់តែបញ្ចូលនូវឧបករណ៍បញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដែលចាំបាច់ប៉ុណ្ណោះ ។

ខ. ឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ផ្អែកតាមស្ថានភាពខេត្តពោធិសាត់ទាំងមូល ។

គ. ឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវមានលក្ខណៈសាមញ្ញ និង ខ្លី បំផុត ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

ក្រៅពីក្របខ័ណ្ឌដែលបានបរិយាយខាងលើ បទពិសោធន៍ និងចំណេះដឹងមូលដ្ឋានខាងក្រោមនេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះនៃការពិភាក្សា :

- ចំណេះដឹងដែលបានទទួលការបណ្តុះបណ្តាលវគ្គទី១អំពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងធនធានធម្មជាតិ
- បទពិសោធន៍ដែលទទួលបានពីដំណើរទស្សនៈកិច្ចសិក្សា ទៅកាន់ខេត្តរតនគិរី
- ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់
- បទពិសោធន៍ការងាររបស់ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ខេត្តពោធិសាត់

ការពិភាក្សា ត្រូវបានធ្វើឡើងរយៈពេល៥ថ្ងៃ នៅថ្ងៃទី២២-២៦ ខែកក្កដា ឆ្នាំ២០០២ ដែលមានដំណើរការជាបន្តបន្ទាប់ដូចខាងក្រោម :

- **ការពិភាក្សាក្រុមធំ** : ការពិភាក្សាលំអិតអំពីដំណើរការ ក្នុងការសំរបសំរួលជាក់ស្តែង នៃផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ក្នុងជំហានទី១ ទី២ ទី៣ ទី៤ និងទី៥ ។ **ជំហានទី១ និងទី២** គឺជាជំហានដ៏សំខាន់បំផុត ក្នុងការបញ្ជ្រាបឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។
- **ការពិភាក្សាក្រុមតូច** : ការពិភាក្សាលំអិតអំពី :
  - ឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
  - លទ្ធភាពបញ្ចូលឧបករណ៍ទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់
- **ការពិភាក្សាក្រុមធំ** : ការពិភាក្សាលំអិត ដើម្បីកែសំរួល និងព្រមព្រៀងអំពីឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។
- **ការសាកល្បងនៅតាមមូលដ្ឋាន** : ឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានសាកល្បង នៅតាមមូលដ្ឋានចំនួន១ថ្ងៃ ។

ជាលទ្ធផល អង្គពិភាក្សាទាំងមូល បានសំរេចដាក់បញ្ចូលឧបករណ៍នៃការបញ្ជ្រាប NREM ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ដូចខាងក្រោមនេះ :

| ផែនការអភិវឌ្ឍន៍ឃុំ | ការបញ្ចូលឧបករណ៍នៃការបញ្ជ្រាប NREM |
|---|---|
| **ជំហានទី១ :** | |
| ក) ពិនិត្យផ្ទៀងផ្ទាត់ ទិន្នន័យធៀបទៅនឹងស្ថានភាពជាក់ស្តែងរបស់ឃុំ-សង្កាត់ ។ | |
| ខ) កែសំរួលផែនទីឃុំ សង្កាត់ ។ | • ផែនទីសង្គម និងធនធានធម្មជាតិ ។<br>• ធ្វើការវិភាគស្ថានភាពធនធានធម្មជាតិ ។ |
| គ) កំណត់តំរូវការ ឬបញ្ហា ។ | |
| ឃ) ការពង្រឹងសមត្ថភាព តំណាងភូមិដើម្បីដំណើរការពិនិត្យសុពលភាពទិន្នន័យ និងកំណត់អាទិភាពនៃបញ្ហានៅថ្នាក់ភូមិ ។ | • អ្នកសំរបសំរួល/ក្រុម ពង្រឹងសមត្ថភាព គ.ជ.ថ អោយចេះបំផុសសំណួរ ដែលទាក់ទងទៅនឹងផ្នែកទាំង៥នៃក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ឃុំ (សេដ្ឋកិច្ច សង្គមកិច្ច ការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន យេនឌ័រ និងសេវាកម្មរដ្ឋបាល-សន្តិសុខ) |

| ផែនការអភិវឌ្ឍន៍ឃុំ | ការបញ្ចូលឧបករណ៍នៃការបញ្ជ្រាប NREM |
|---|---|
| **ជំហានទី២ :** | |
| ក) ពិនិត្យមើលទិន្នន័យភូមិ និងផែនទី ដែលបានពីថ្នាក់ឃុំ-សង្កាត់ និងធ្វើសុពលភាព ។ | • បង្ហាញផែនទីឃុំ/ភូមិដល់អ្នកភូមិ ។<br>• បង្ហាញលទ្ធផលនៃការវិភាគស្ថានភាពធនធានធម្មជាតិ ដែលបានរៀបចំនៅសកម្មភាព "ខ" នៃជំហានទី១ ។ |
| ខ) ប្រជុំភូមិ ដើម្បី :<br>• កំណត់បញ្ហា និងតំរូវ ការជាអាទិភាពរបស់អ្នកភូមិ<br>និង<br>• ពិចារណាពីលទ្ធភាព ធនធានដែលអាចមាននៅក្នុងភូមិ ។ | • បំផុសសំណួរ ដែលទាក់ទងទៅនឹងផ្នែកទាំង៥ នៃក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ឃុំ (សេដ្ឋកិច្ច សង្គមកិច្ច ការគ្រប់គ្រងធនធានធម្ម ជាតិ-បរិស្ថាន យេនឌ័រ និងសេវាកម្មរដ្ឋបាល-សន្តិសុខ) |

ឧបសម្ព័ន្ធទី៦ : ការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

**កំណត់សំគាល់ :**

- អក្សរបទនាបទ Limon S2 មានគូរបន្ទាត់ពីក្រោម (និងពណ៌ខៀវ) នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ គឺជាលទ្ធផលនៃកិច្ចពិភាក្សា ក្នុងការបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។

## ៦.២ ការចុះដកស្រង់បទពិសោធន៍អំពីដំណើរការនៃការកសាងផែនការឃុំ-សង្កាត់

ដើម្បីបង្កើតចំណេះដឹង និងបទពិសោធន៍ អំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ក្រុម NREM-TFT បានចូលរួមក្នុងការអនុវត្តន៍ការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ពីជំហានទី១ ដល់ទី៥ (សំរាប់ជុំទី១ នៃការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ របស់ខេត្តពោធិសាត់) រយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី០១-១១ ខែសីហា ឆ្នាំ២០០២ ។ នៅក្នុងពេលនេះ ក្រុម NREM-TFT បាន :

- ផ្តោតការយកចិត្តទុកដាក់ទៅលើវិធីសាស្ត្រ ក្នុងការសំរបសំរួលផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។
- ធ្វើការសាកល្បងនូវឧបករណ៍បញ្ជ្រាប NREM (នៅពេលសំរាក) ។
- ធ្វើការសង្កេតទៅលើដំណើរការនៃការអនុវត្តការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។

## ៦.៣ ការប្រជុំដើម្បីកែសំរួលឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM ឡើងវិញលើកទី១

បន្ទាប់ពីបានចូលរួម និងសាកល្បងឧបករណ៍បញ្ជ្រាប NREM នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ ក្រុម NREM-TFT បានជួបប្រជុំគ្នា រយៈពេល១ថ្ងៃ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ ដើម្បី :

- ធ្វើការបញ្ជាក់បន្ថែមអំពីវិធីសាស្ត្រសំរបសំរួល ក្នុងការកែសំរួលផែនទី ។
- ធ្វើការបញ្ជាក់បន្ថែមអំពីវិធីសាស្ត្រសំរបសំរួល ក្នុងការវិភាគស្ថានភាពធនធានធម្មជាតិ ។
- ធ្វើការកែសំរួលសំណួរសំខាន់ៗ ។

៦.៤ ការប្រជុំដើម្បីកែសំរួលឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM ឡើងវិញលើកទី២

ក្រុម NREM-TFT បានចុះអនុវត្តន៍ផ្ទាល់នៅឃុំគោលដៅទាំង៦ ចាប់ពីថ្ងៃទី១៩ ខែសីហា ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០២ នៅជំហានទី១ ទី២ ទី៣ ទី៤ និងទី៥ ។ បន្ទាប់ពីបានអនុវត្តន៍ផ្ទាល់នេះ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ ក្រុម NREM-TFT បានធ្វើការប្រជុំមួយ ដើម្បីកែសំរួលឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM អោយល់អិតបន្ថែមទៀត :

**ក). ការកែសំរួលផែនទីឃុំ**

- អ្នកសំរបសំរួល សហការជាមួយស្មៀនឃុំ ត្រូវរៀបចំផែនទីព្រាងជាមុន ។
- បង្ហាញផែនទីព្រាងនេះ ដល់អង្គប្រជុំថ្នាក់ឃុំ ដើម្បីធ្វើការកែតំរូវ ។

**ខ). ការវិភាគស្ថានភាពធនធានធម្មជាតិ**

តាមឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM ដែលបានព្រមព្រៀង ការវិភាគស្ថានភាពធនធានធម្មជាតិ ត្រូវបានអនុវត្តន៍នៅសកម្មភាព"ខ" នៃជំហានទី១ (បន្ទាប់ពីការកែសំរួលផែនទីឃុំ) និងសកម្មភាព"ក" នៃជំហានទី២ (បន្ទាប់ពីការផ្ទៀងផ្ទាត់ទិន្នន័យភូមិ និងផែនទីឃុំដែលបានកែសំរួល) ។

- ការវិភាគស្ថានភាពធនធានធម្មជាតិ ដែលត្រូវបានអនុវត្តន៍នៅសកម្មភាព"ខ" នៃជំហានទី១ (បន្ទាប់ពីការកែសំរួលផែនទីឃុំ) ត្រូវបានរក្សាទុកដដែល ។
- ការវិភាគស្ថានភាពធនធានធម្មជាតិ ដែលត្រូវបានអនុវត្តន៍នៅសកម្មភាព"ក" នៃជំហានទី២ (បន្ទាប់ពីការផ្ទៀងផ្ទាត់ទិន្នន័យភូមិ និងផែនទីឃុំដែលបានកែសំរួល) ត្រូវបានប្តូរទៅជា ការបង្ហាញលទ្ធផលនៃការវិភាគស្ថានភាពធនធានធម្មជាតិ ដែលត្រូវបានអនុវត្តន៍នៅសកម្មភាព"ខ" នៃជំហានទី១ ដើម្បីកែសំរួល និងព្រមព្រៀង ។

**គ). សំណួរគន្លឹះ ឬសំណួរសំខាន់ៗ**

សំណួរគន្លឹះ ត្រូវបានល់អិតទាំង៥ផ្នែកនៃក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ឃុំ ដែលពីដំបូង សំណួរគន្លឹះនេះ បានផ្តោតទៅលើតែធនធានធម្មជាតិ និងកសិកម្មប៉ុណ្ណោះ ។

**ឃ). កំណត់សំគាល់ និងអនុសាសន៍**

- ផែនទីឃុំដែលបានកែសំរួលនេះ ត្រូវតែធ្វើការបង្ហាញនៅក្នុងសកម្មភាព "ក" នៃជំហានទី២ (បន្ទាប់ពីការផ្ទៀងផ្ទាត់ទិន្នន័យភូមិ) ដើម្បីអោយអ្នកភូមិចូលរួមផ្តល់យោបល់កែលំអ និងផ្តល់ការព្រម

ព្រៀង ជាចាំបាច់ណាស់ ទោះបីជា គ.ផ.ថ បានដឹងច្បាស់អំពីធនធានធម្មជាតិដែលមាននៅក្នុងភូមិរបស់ពួកគេក៏ដោយ ។ ការបង្ហាញនេះ នឹងត្រូវការពេលវេលាប្រហែលចំនួន១ម៉ោងប៉ុណ្ណោះ ។

- ការវិភាគស្ថានភាពធនធានធម្មជាតិ ជាមួយអ្នកភូមិ នឹងមិនត្រូវបានអនុវត្តន៍ទេ ដោយគ្រាន់តែធ្វើការបង្ហាញលទ្ធផលនៃការវិភាគស្ថានភាពធនធានធម្មជាតិឃុំ (ដែលបានអនុវត្តនៅសកម្មភាព "ខ" នៃជំហានទី១) ដល់អ្នកភូមិ ដើម្បីកែសំរួល និងព្រមព្រៀង ។ ការបង្ហាញនេះ នឹងត្រូវការពេលវេលាប្រហែលចំនួន១ម៉ោង ។
- ការផ្ទៀងផ្ទាត់ទិន្នន័យភូមិ/ឃុំ នៅក្នុងជំហានទី១ បានចំណាយពេលច្រើនពេក ។ ជាការប្រសើរទិន្នន័យភូមិ/ឃុំទាំងនេះ ត្រូវបានរៀបចំជាស្រេចមុនការប្រជុំ ដោយស្មៀនឃុំ និងក្រុមប្រឹក្សាឃុំ ។ ជំហានទី១ គឺជាជំហានដ៏សំខាន់មួយ ក្នុងការពង្រឹងសមត្ថភាព គ.ផ.ថ ដើម្បីអោយពួកគាត់ មានលទ្ធភាពក្នុងការសំរបសំរួលការងារនៅជំហានទី២ ដូចនេះត្រូវមានពេលវេលាគ្រប់គ្រាន់ ។ នៅជំហានទី១នេះ គួរត្រូវបានប្រើប្រាស់រយៈពេល៣ថ្ងៃពេញ ។
- ជំហានទី២ គឺជាជំហានដ៏សំខាន់បំផុត ដែលអ្នកភូមិត្រូវបានអញ្ជើញចូលរួមផ្តល់មតិយោបល់ និងផ្តល់ការព្រមព្រៀងដោយផ្ទាល់ ។ នៅជំហានទី២នេះ ត្រូវបានចំណាយពេលតែមួយថ្ងៃ ហើយបានផ្តោតតែទៅលើសកម្មភាព "ខ១" ប៉ុណ្ណោះ (សកម្មភាព "ក" ពុំត្រូវបានអនុវត្តទេ) ។ សកម្មភាពទាំង២នៃជំហានទី២នេះ គួរត្រូវបានអនុវត្តន៍អោយបានពេញលេញ ដោយរយៈពេល២ថ្ងៃពេញ ។
- បញ្ហា/តំរូវការជាអាទិភាព នៅក្នុងភូមិទាំងអស់នៃឃុំគោលដៅទាំង៦ មានលក្ខណៈប្រហាក់ប្រហែលគ្នា ទោះបីជាភូមិដែលក្រុម NREM-TFT មិនបានចុះជួយក៏ដោយ ។ នេះអាចបញ្ជាក់អោយឃើញថា ឧបករណ៍បញ្ហាបធនធានធម្មជាតិ និងបរិស្ថាន អាចប្រើប្រាស់បាន និងឆ្លើយតបទៅនឹងគោលបំណង ។
- ការបញ្ជាក់បន្ថែមទៅលើនិយមន័យនៃផ្នែកទាំង៥ : រាល់សកម្មភាព/បញ្ហា/តំរូវការ និងការបណ្តុះបណ្តាលទាំងឡាយ ដែលមានភាពជាក់លាក់ទាក់ទងទៅនឹងផ្នែកទាំង៤ (សេដ្ឋកិច្ច NREM យេនឌ័រ និងសេវាកម្មរដ្ឋបាល-សន្តិសុខ) សូមបញ្ចូលទៅតាមផ្នែកនីមួយៗ ។ ក្រៅពីនេះ សូមបញ្ចូលទៅក្នុងផ្នែកសង្គមកិច្ច ។ ធ្វើបែបនេះ ដើម្បីអោយសកម្មភាពនានា មានលក្ខណៈប្រមូលផ្តុំ ហើយងាយស្រួលដល់ការរៀបចំគំរោង ។

## ៧ ឧបករណ៍ និងវិធីសាស្រ្តបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

### ៧.១ ផែនទីឃុំ (ភូមិ) : ដើម្បីបង្ហាញអំពីធនធានធម្មជាតិដែលមាននៅក្នុងឃុំ (ភូមិ) ។

- រៀបចំផែនទីព្រាង នៅលើផ្ទាំងក្រដាស់ធំជាមុន (សហការជាមួយស្មៀនឃុំ) ។

- បង្ហាញផែនទីព្រាងនេះ ដើម្បីធ្វើការកែតំរូវទៅលើ : ១).ព្រំប្រទល់ភូមិ/ឃុំ ២).ផ្លូវថ្នល់ ៣).ផ្លូវទឹក ៤)..... ល និង ល ។
- តើមានធនធានធម្មជាតិអ្វីខ្លះ? (ដូចជាទន្លេ បឹង ស្ទឹង ព្រៃ រ៉ែ រមណីយដ្ឋានធម្មជាតិ ...) បើចាំបាច់ពាក្យ និងសារៈប្រយោជន៍នៃធនធានធម្មជាតិ គួរត្រូវបានពន្យល់ ។
- តើធនធានធម្មជាតិអ្វីខ្លះដែលបានបាត់បង់?
- កំណត់និមិត្តសញ្ញា ប្រសិនបើចាំបាច់ ។
- បញ្ចូលនិមិត្តសញ្ញាទាំងនេះ ទៅក្នុងផែនទី ។

### ៧.២ ការវិភាគស្ថានភាពធនធានធម្មជាតិ (ផ្សាក្រាម និងនិន្នាការ)

ការវិភាគស្ថានភាពធនធានធម្មជាតិ ដើម្បីអោយអ្នកចូលរួមបានយល់ច្បាស់អំពីស្ថានភាពធនធានធម្មជាតិពីអតីតកាល និងបច្ចុប្បន្ន និងមូលហេតុពិតប្រាកដដែលបណ្តាលអោយមានការប្រែប្រួល ។

**ក). គំរូទី១**



ខ). គំរូទី២

| ល.រ | ប្រភេទធនធានធម្មជាតិ | ការដាក់ពិន្ទុ | | បញ្ហា/មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|---|---|
| | | បច្ចុប្បន្ន | ពីមុន | | |
| | | | | | |
| | | | | | |

- ដកស្រង់នូវរាល់ធនធានធម្មជាតិ ដែលមាននៅលើផែនទី ។
- ដាក់ពិន្ទុពី ១ ដល់ ១០ ( បច្ចុប្បន្នកាល និងពីអតីតកាល) ។
- មូលហេតុដែលបណ្តាលអោយប្រែប្រួល ( បញ្ហា) ។
- ដំណោះស្រាយ ឬតំរូវការ ។

៧.៣ សំណួរគន្លឹះ ឬសំណួរសំខាន់ៗ ទាក់ទងទៅនឹងផ្នែកទាំង៥នៃក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ឃុំ

- តើភូមិយើងជួបប្រទះបញ្ហា/លំបាក ឬត្រូវការ/ចង់បានអ្វីខ្លះ?

សំណួរគន្លឹះទាំងនេះ គឺសំរាប់ជាជំនួយដល់អ្នកសំរបសំរួល ក្នុងការសំរបសំរួលក្រុមពិភាក្សាដើម្បីកំណត់អាទិភាពភូមិ/ឃុំ ។

៧.៣.១ សំណួរគន្លឹះដំបូងមុនពេលចុះអនុវត្តន៍សាកល្បង

ក). ការដាំដុះ

- ការធ្វើស្រូវ ( ស្រូវវស្សា និងប្រាំង) ការដាំបន្លែ ការធ្វើចំការ និងឈើហូបផ្លែ ។
- ទិន្នផល ( មូលហេតុបណ្តាលអោយទិន្នផលស្រូវទាប)
- សត្វល្អិត និងសត្វបំផ្លាញ ( ឬជំងឺផ្សេងៗ)
- គុណភាពដី
- ទឹកសំរាប់ធ្វើកសិកម្ម
- តំលៃកសិកផលលើទីផ្សារ
- ពូជ សំភារៈ-បរិក្ខាកសិកម្ម និងកំលាំងអូសទាញ

ខ). ការចិញ្ចឹមសត្វ

- ជំងឺសត្វ
- ចំណីសត្វ ( និងការលួចលាស់)

- តំលៃសត្វនៅទីផ្សារ
- សេវាកម្មព្យាបាលសត្វឈឺ
- ពូជសត្វ ។

**គ). ជលផល**

- ការនេសាទ និងការធ្វើអាជីវកម្មនេសាទ
- ផលនេសាទ
- ជំរកត្រីពងកូន ( និងលូគលាស់)
- ពូជត្រីសំខាន់ៗដែលស្ទើរតែ ឬបាត់បង់ ។
- ការចិញ្ចឹមត្រី ។

**ឃ). អនុផលព្រៃឈើ និងរ៉ែ**

- ការប្រមូលអនុផលព្រៃឈើ ( សំរាប់ជីវភាពរស់នៅ)
- ការកាប់ឈើអាណាធិបតេយ្យ
- ការចាប់យកជីព្រៃ និងការរានដីព្រៃ
- ទំនាស់ ឬវិវាទ ( ព្រំប្រទល់)
- ការធ្វើអាជីវកម្មរ៉ែ
- រមណីដ្ឋានធម្មជាតិ
- ពូជកូនឈើ

៧.៣.២ សំណួរគន្លឹះបានកែសំរួលបន្ទាប់ពីចុះអនុវត្តន៍សាកល្បង

**ផ្នែកទី១ : សេដ្ឋកិច្ច**

**១-ក. ការដាំដុះ**

- ប្រភេទដំណាំ :
  - ដំណាំស្រូវ ( ស្រូវវស្សា : ស្រាល កណ្តាល ធ្ងន់ និងឡើងទឹក ស្រូវប្រាំង : ប្រកាន់រដូវ និងមិនប្រកាន់រដូវ និងស្រូវចំការ)
  - ដំណាំបន្លែ ( ប្រភេទស្លឹក/ដើម/ផ្កា មើម និងផ្លែ)
  - ដំណាំឈើហូបផ្លែ
  - ដំណាំចំការ ( ប្រភេទធុញ្ញជាតិ-ពោត សណ្តែក ល្ង... ប្រភេទមើម-ដំឡូងឈ្វា ដំឡូងឈើ.... និងឧស្សាហកម្ម-អំពៅ កៅស៊ូ តែ ស្វាយចន្ទី កប្បាស ម្រេច គរ...... ។

- ទិន្នផល ( មូលហេតុបណ្តាលអោយទិន្នផលស្រូវទាប)
- សត្វល្អិត និងសត្វបំផ្លាញ (ឬជំងឺផ្សេងៗ)
- គុណភាពដី
- ទឹកសំរាប់ធ្វើកសិកម្ម
- តំលៃកសិកផលលើទីផ្សារ
- ពូជដំណាំ ( បញ្ជាក់ប្រភេទពូជអោយច្បាស់លាស់)
- សំភារៈ-បរិក្ខាកសិកម្ម និងកំលាំងអូសទាញ ។
- ការបណ្តុះបណ្តាលបច្ចេកទេស (សូមបញ្ជាក់ប្រធានបទអោយបានច្បាស់លាស់) ។

## ១-ខ. ការចិញ្ចឹមសត្វ

- ជំងឺសត្វ
- ចំណីសត្វ ( និងការលួចលាស់)
- តំលៃសត្វនៅទីផ្សារ
- សេវាកម្មព្យាបាលសត្វឈឺ
- ពូជសត្វ ( សូមបញ្ជាក់ប្រភេទសត្វអោយបានច្បាស់លាស់) ។
- ការបណ្តុះបណ្តាលបច្ចេកទេស (សូមបញ្ជាក់ប្រធានបទអោយបានច្បាស់លាស់) ។

## ១-គ. ជលផល

- ការនេសាទ និងការធ្វើអាជីវកម្មនេសាទ
- ផលនេសាទ
- ការចិញ្ចឹមត្រី (ក្នុងស្រះ ឬក្នុងស្រែ) ។
- ពូជត្រី (សូមបញ្ជាក់ប្រភេទសត្វអោយបានច្បាស់លាស់) ។
- ការបណ្តុះបណ្តាលបច្ចេកទេស (សូមបញ្ជាក់ប្រធានបទអោយបានច្បាស់លាស់) ។

## ១-ឃ. ធារាសាស្ត្រ

- ជីកប្រឡាយ (ប្រឡាយមេ ឬប្រឡាយរង) ។
- ស្តារ ឬជួសជុលប្រឡាយ (ប្រឡាយមេ ឬប្រឡាយរង) ។
- លើកទំនប់ថ្មី ។
- ជួសជុលទំនប់ចាស់ ។
- ធ្វើទ្វារទឹកថ្មី ។
- ជួសជុលទ្វារទឹកចាស់ ។

### ១-ង. ផ្លូវគមនាគមន៍

- លើកផ្លូវលំដីស ។
- ជួសជុសផ្លូវលំដីស ។
- ក្រាលគ្រួសក្រហម ។
- ជួសជុសផ្លូវគ្រួសក្រហម ។
- លូកាត់ផ្លូវ ( បញ្ជាក់ប្រភេទលូ ) ។
- ស្ពាន ( ប្រភេទស្ពាន ដូចជាស្ពានឈើក្បាលបេតុង ) ។

### ១-ច. ឥណទាន

- ឥណទាន
- ។ល ។

## ផ្នែកទី២ : សង្គមកិច្ច

### ២-ក. អប់រំ

- សាងសង់សាលារៀន ( សាបឋមសិក្សា ឬមធ្យមសិក្សា ឬសាលាមត្តេយ្យ) ។
- ជួសជុលសាលារៀន ( សាបឋមសិក្សា ឬមធ្យមសិក្សា ឬសាលាមត្តេយ្យ) ។
- ទីចាត់ការសាលារៀន ។
- ក្លោងទ្វារ និងរបងសាលារៀន ។
- សំភារៈកីឡាសិស្ស ។
- បណ្តុះបណ្តាលបង្កើនសមត្ថភាពគ្រូបង្រៀន ។
- បើកថ្នាក់អក្ខរកម្ម ។

### ២-ខ. ទឹកស្អាត

- ជីកអណ្តូង ( អណ្តូងស្នប់ ឬអណ្តូងលូ) ។
- ជួសជុលអណ្តូង ( អណ្តូងស្នប់ ឬអណ្តូងលូ) ។
- ស្រះទឹក ( ស្រះសហគមន៍ ឬស្រះគ្រួសារ ) ។
- អាងចំរោះទឹក ។

### ២-គ. សុខភាព

- កម្មវិធីចាក់វ៉ាក់សាំងការពារ ( ជំងឺ៦មុខរបស់កុមារ ឬជំងឺតេតាណូស) ។
- កម្មវិធីផ្សព្វផ្សាយជំងឺគ្រុនចាញ់ និងជំងឺអេដស៍ ។

- កម្មវិធីផ្សព្វផ្សាយការពន្យាលកំណើត ។
- កម្មវិធីផ្សព្វផ្សាយការអប់រំសុខភាពស្ត្រី និងកុមារ ។
- ការអប់រំសុខភាពបឋម ។
- សាងសង់បង្គន់អនាម័យ ។
- ការបណ្តុះបណ្តាលឆ្មបភូមិ និងឆ្មបបូរាណ ។
- ការបណ្តុះបណ្តាលបច្ចេកទេស ( សូមបញ្ជាក់ប្រធានបទអោយបានច្បាស់លាស់) ។
- បរិក្ខាពេទ្យសំរាបប៉ុស្តិសុខភាពឃុំ ។
- មណ្ឌល/ប៉ុស្តិសុខភាព ។

## ២-ឃ. ការបណ្តុះបណ្តាលវិជ្ជាជីវៈ

- ការបណ្តុះបណ្តាលវិជ្ជាជីវៈ ( ម៉ូតូ កាត់ដេរ អ៊ុតសក់ វិទ្យុ ទូរទស្សន៍ ចម្លាក់ តំបាញ់កន្ទេល ជាងកំបោរ ជាងស័ង្កសី ជាងឈើ និងគ្រឿងម៉ាស៊ីគ្រប់ប្រភេទ) ។
- ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ ស្ត្រីមេម៉ាយ និងកុមារកំព្រា ។

## ២-ង. ផ្សេងៗ

- បង្កើតសមាគមជួយចាស់ជរា ។
- បង្កើតសមាគមយុវជន ។
- អប់រំក្មេងពាល ។
- សាលាឆទាន ។
- កសាងវត្តអារាម ។
- ដោះមីន ។

# ផ្នែកទី៣ : ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

- ការប្រមូលអនុផលព្រៃឈើ និងការបរបាញ់សត្វព្រៃ ( សំរាប់ជីវភាពរស់នៅ) ។
- ការកាប់ឈើអាណាធិបតេយ្យ ។
- ភាពអាណាធិបតេយ្យនៃការធ្វើអាជីវកម្មអនុផលព្រៃឈើ ។
- ភាពអាណាធិបតេយ្យទៅលើព្រៃលិចទឹក និងធនធានជលផល ។
- ជំរកត្រីពងកូន ( និងលូតលាស់)
- ពូជត្រីសំខាន់ៗដែលស្ទើរតែ ឬបាត់បង់ ។
- ការចាប់យកដីព្រៃ និងការកាប់រានដីព្រៃ ។

- ទំនាស់ ឬវិវាទ ( ព្រំប្រទល់ ) ។
- ការធ្វើអាជីវកម្មរ៉ែ ។
- រមណីដ្ឋានធម្មជាតិ ។
- ពូជកូនឈើ ។
- ការបណ្តុះបណ្តាល ( សូមបញ្ជាក់ប្រធានបទអោយបានច្បាស់លាស់ ) ។
- ការផ្សព្វផ្សាយច្បាប់ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ ដូចជាច្បាស់ភូមិបាល ច្បាស់បរិស្ថាន ច្បាប់ព្រៃឈើ អនុក្រិត្យស្តីអំពីការបង្កើតសគមន៍ព្រៃឈើ ច្បាប់ជលផល អនុក្រិត្យស្តីអំពីការបង្កើតសគមន៍នេសាទ ។ល។

**ផ្នែកទី៤ : សេវាកម្មរដ្ឋបាល និងសន្តិសុខ**

- ការងារសន្តិសុខក្នុងឃុំ ( ចោរកម្ម ការជួញដូរស្ត្រី-កុមារ .......) ។
- ការធ្វើអត្រានុកូលដ្ឋាន និងការប្រមូនទិន្នន័យ ។
- ការផ្សព្វផ្សាយច្បាប់នានា : ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់រដ្ឋបវេណី ច្បាប់ព្រហ្មទណ្ឌ សិទ្ធមនុស្ស ។ល។
- ប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លី ។
- សាលាឃុំ និងស្នាក់ញការភូមិ ព្រមទាំងសម្ភារីម និងបរិក្ខា ។
- ការបណ្តុះបណ្តាល ( សូមបញ្ជាក់ប្រធានបទអោយបានច្បាស់លាស់ ) ។

**ផ្នែកទី៥ : យេនឌ័រ**

| |
|---|
| រាល់ការងារ ឬសកម្មភាពទាំងឡាយណា ដែលផ្តល់អត្ថប្រយោជន៍ជាពិសេសដល់ស្ត្រី : |
| - ជួយលើកកំពស់ជីវភាពស្ត្រី ។ |
| - ជួយលើកកំពស់ឋានៈស្ត្រី នៅក្នុងសង្គម ។ |
| - បង្កើនចំណេះដឹងដល់ស្ត្រី ។ |
| - ការងារកាត់បន្ថយបន្ទុកការងារស្ត្រី ។ |

- កម្មវិធីផ្សព្វផ្សាយដើម្បីលុបបំបាត់អំពើហឹង្សាក្នុងគ្រួសារ ។
- កម្មវិធីផ្សព្វផ្សាយដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ ។
- ការបណ្តុះបណ្តាលអំពីយេនឌ័រ ។
- បង្កើត និងពង្រីកជនបង្គោលស្ត្រីនៅតាមមូលដ្ឋាន ។

### ៧.៤ តំរូវការពេលវេលា ក្នុងការអនុវត្តឧបករណ៍បញ្ច្រាប NREM

| លរ | ការបរិយាយ | រយៈពេល |
|---|---|---|
| ជំហានទី១ | | |
| ១ | សកម្មភាព "ខ" : ការកែសំរួលផែនទីឃុំ ។ | ៣ម៉ោង ( កន្លះថ្ងៃ) |
| ២ | សកម្មភាព "ខ" : ការវិភាគស្ថានភាពធនធានធម្មជាតិ ។ | ២ម៉ោង |
| ៣ | សកម្មភាព "ឃ" : ការពង្រឹងសមត្ថភាព គ.ជ.ឋ ។ | ៣ម៉ោង ( កន្លះថ្ងៃ) |
| ជំហានទី២ | | |
| ៤ | សកម្មភាព "ក" : ការបង្ហាញផែនទីដែលបានកែសំរួលរួច ។ | ១ម៉ោង |
| ៥ | សកម្មភាព "ក" : ការបង្ហាញលទ្ធផលនៃការវិភាគធនធានធម្មជាតិ ។ | ១ម៉ោង |
| ៦ | សកម្មភាព "ខ" : ការកំណត់បញ្ហា/តំរូវការជាអាទិភាពរបស់អ្នកភូមិ ។ | ១ថ្ងៃពេញ |

## ៨ ការរៀបចំសំរាប់ការអនុវត្ត

### ៨.១ សំណើបែងចែកការងារ នៅក្នុងការសំរបសំរួលការកសាងផែនការអភិវឌ្ឍន៍ឃុំ

ក្រុម NREM-TFT បានឯកភាពដូចខាងក្រោម :

| ជំហាន និងសកម្មភាព | | ក្រុមNREM-TFT | ក្រុមសំរបសំរួលស្រុក |
|---|---|---|---|
| ជំហានទី១ : | សកម្មភាព "ក" | | X |
| | សកម្មភាព "ខ" | X | |
| | សកម្មភាព "គ" | | X |
| | សកម្មភាព "ឃ" | V | V |
| ជំហានទី២ : | សកម្មភាព "ក" | ជួយ គ.ជ.ឋ | ជួយ គ.ជ.ឋ |
| | សកម្មភាព "ខ" | ជួយ គ.ជ.ឋ | ជួយ គ.ជ.ឋ |
| ជំហានទី៣ : | សកម្មភាព "ក" | V | V |
| | សកម្មភាព "ខ" | V | V |
| ជំហានទី៤ : | សកម្មភាព "ក" | V | V |
| | សកម្មភាព "ខ" | V | V |
| ជំហានទី៥ : | សកម្មភាព "ក" | V | V |

**កំណត់សំគាល់ :**

- X : មានន័យថា ជាអ្នកសំរបសំរួលសកម្មភាពទាំងស្រុង ។
- V : មានន័យថា ជាអ្នកសំរបសំរួលសកម្មភាពតាមផ្នែក ។
- ក្រុម NREM-TFT សំរបសំរួល និងជួយតែទៅលើផ្នែកការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន និងសេដ្ឋកិច្ច-កសិកម្ម ប៉ុណ្ណោះ ។

### ៨.២ ការបែងចែកការងារឃុំគោលដៅ :

ក្រុម NREM-TFT បានឯកភាពទៅលើគោលការណ៍ ក្នុងការបែងចែកឃុំគោលដៅសំរាប់ទទួលខុសត្រូវ ដូចខាងក្រោម :

- ស្ត្រី ត្រូវបានផ្តល់អាទិភាព ក្នុងការជ្រើសរើសមុនគេ ។
- អ្នកស្ម័គ្រចិត្តទទួលយកឃុំដែលឆ្ងាយ និងលំបាកជាងគេ ដូចជាឃុំនៅស្រុកវាលវែងជាដើម ។
- អ្នកស្ម័គ្រចិត្តទទួលយកឃុំដែលឆ្ងាយជាងគេបន្ទាប់ ។

លទ្ធផលនៃការបែងចែកឃុំគោលដៅ សំរាប់ការទទួលខុសត្រូវ :

| លរ | ឃុំ | ស្រុក | ចំនួនភូមិ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ១ | អូរសណ្តាន់ | ក្រគរ | ៧ | ជ័យ ចន្ទី |
| ២ | អន្សាចំបក់ | ក្រគរ | ៧ | ជុំ សារ៉ាល់ |
| ៣ | តាលោ | បាកាន | ១៩ | មាស ប៊ុនធឿន |
| ៤ | អូរតាប៉ោង | បាកាន | ១៨ | កុំ ថាយ |
| ៥ | ប្រម៉ោយ | វាលវែង | ៥ | អ៊ឹម សុភី |
| ៦ | អន្លង់រាប | វាលវែង | ៥ | ស្វូន ច័ន្ទឌី |
| សរុប | ៦ឃុំ | ៣ស្រុក | ៦១ភូមិ | ៦នាក់ |

## ៩ ការបណ្តុះបណ្តាលអំពីឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន ដល់ក្រុមសំរបសំរួលស្រុក-ខេត្ត ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ

តាមគំរោង ក្រុម NREM-TFT នឹងធ្វើការបណ្តុះបណ្តាលអំពីឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន រយៈពេល៣ថ្ងៃ ដល់ក្រុមសំរបសំរួលស្រុក/ខេត្ត ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការកសាងផែនការ-ថវិកា (គ.ផ.ថ) ប៉ុន្តែការបណ្តុះបណ្តាលនេះ ពុំត្រូវបានអនុវត្តនោះទេ ដោយសារមូលហេតុ :

- ការបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន មានការយឺតយ៉ាវបន្តិច ដែលជាហេតុនាំអោយការបណ្តុះបណ្តាលអំពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដល់ក្រុមប្រឹក្សា

ឃុំ-សង្កាត់ និង គ.ផ.ថ ត្រូវបានបញ្ចប់ជាស្ថាពរមុន ។

- ក្រុមសំរបសំរួលស្រុក និងខេត្ត កំពុងជាប់រវល់អនុវត្តការកសាងផែនការអភិវឌ្ឍន៏ឃុំជុំទី១ ។

ដើម្បីដោះស្រាយនូវបញ្ហានេះ ក្រុម NREM-TFT បានអនុវត្តដូចខាងក្រោម :

ក). សំរាប់ក្រុមសំរបសំរួលស្រុក និងខេត្ត :

- ក្រុម NREM-TFT បានរៀបចំការប្រជុំមួយ ជាមួយនឹងក្រុមសំរបសំរួលស្រុក-ខេត្ត ដើម្បីបង្ហាញអំពីឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន ។
- បែងចែកសកម្មភាពនៃការកសាងផែនការអភិវឌ្ឍន៏ឃុំ សំរាប់សំរបសំរួល ។

ខ). សំរាប់ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ :

- ក្រុម NREM-TFT បានធ្វើការបណ្តុះបណ្តាលដោយអនុវត្តជាក់ស្តែង នៅក្នុងពេលអនុវត្តការកសាងផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់តែម្តង ។

## ១០ លទ្ធផលនៃការអនុវត្ត NMTM នៅឃុំគោលដៅទាំង៦

ក្រុម NREM-TFT បានចុះអនុវត្តផ្ទាល់នៅឃុំគោលដៅទាំង៦ ចាប់ពីថ្ងៃទី១៩ ខែសីហា ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០២ នៅជំហានទី១ ទី២ ទី៣ ទី៤ និងទី៥ ។

**ខាងក្រោមនេះ គឺជាលទ្ធផលនៃការអនុវត្តន៍ និងអនុសាសន៍មួយចំនួន :**

ដើម្បីអោយដំណើរការនៃការសំរបសំរួល ការកសាងផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់ ប្រព្រឹត្តិទៅបានល្អ ក្រុម NREM-TFT ក្រុមសំរបសំរួលស្រុក និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បានប្រជុំគ្នា ដើម្បី :

- បញ្ជាក់បន្ថែមអំពីផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់ ដែលបានដាក់បញ្ចូល NMTM ឡើងវិញ ។
- បែងចែកសកម្មភាព សំរាប់សំរបសំរួល ។

### ១០.១ ការសំរបសំរួលរបស់ក្រុម NREM-TFT ក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ

| ការពិពណ៌នា | | ប្រម៉ោយ | អន្លង់រាប | អូរសោណ្តាន់ | អន្សាចំបក់ | អូរតាប៉ោង | តាលោ |
|---|---|---|---|---|---|---|---|
| ជំហានទី១ : | សកម្មភាព "ក" | | X | | | | |
| | សកម្មភាព "ខ" | X | X | X | X | X | X |
| | សកម្មភាព "គ" | | X | | | | |
| | សកម្មភាព "ឃ" | V | X | V | V | V | V |
| ជំហានទី២ : | សកម្មភាព "ក" | | | | | ជួយ គផថ | |
| | សកម្មភាព "ខ១" | ជួយ គផថ | ជួយ គផថ | ជួយ គផថ | ជួយ គផថ | ជួយ គផថ | ជួយ គផថ |
| | សកម្មភាព "ខ២" | | | | | | |

| ការពិពណ៌នា | | ប្រម៉ោយ | អន្លង់រាប | អូរសណ្តាន់ | អន្សាចំបក់ | អូរតាចោង | តាលោ |
|---|---|---|---|---|---|---|---|
| ជំហានទី៣ : | សកម្មភាព "ក" | V | V | V | V | V | V |
| | សកម្មភាព "ខ" | V | V | V | V | V | V |
| ជំហានទី៤ : | សកម្មភាព "ក" | V | V | V | V | V | V |
| | សកម្មភាព "ខ" | V | V | V | V | V | V |
| ជំហានទី៥ : | សកម្មភាព "ក" | V | V | V | V | V | V |
| ចំនួនភូមិដែលក្រុមបានចុះជួយ | | ២ | ៥ | ២ | ៤ | ៥ | ៤ |
| ការចូលរួមរបស់ក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុក នៅជំហានទី១ | | ២ថ្ងៃ | | | ២ថ្ងៃ | | ១ថ្ងៃ |

## ១០.២ ការកែសំរួលផែនទីឃុំ

ការកែសំរួលផែនទីឃុំ ត្រូវបានអនុវត្តនៅសកម្មភាព "ខ" នៃជំហានទី១ ។ ជាលទ្ធផលផែនទីឃុំទាំង៦ឃុំ សុទ្ធតែបានញូលនូវធនធានធម្មជាតិ (សូមអានសៀវភៅផែនការអភិវឌ្ឍន៍ឃុំទាំង៦ ដែលមានរក្សាទុកនៅអង្គភាពរដ្ឋបាលមូលដ្ឋានរបស់ ប្រគ នៃ គអជខ និងសាលាឃុំ) ។ ការសំរបសំរួល ត្រូវការពេលវេលាប្រហែល៣ម៉ោង (កន្លះថ្ងៃ) ប្រសិនបើ ការគូរផែនទីព្រាង នៅលើផ្ទាំងក្រដាស់ធំ ត្រូវបានរៀបចំជាមុន ។

ផែនទីឃុំដែលបានកែសំរួលនេះ នឹងត្រូវបានបង្ហាញនៅក្នុងសកម្មភាព "ក" នៃជំហានទី២ (បន្ទាប់ពីការផ្ទៀងផ្ទាត់ទិន្នន័យភូមិ) ដោយ គ.ផ.ថ ដើម្បីអោយអ្នកភូមិចូលរួមផ្តល់យោបល់កែលំអ និងផ្តល់ការព្រមព្រៀង ។ ក៏ប៉ុន្តែកិច្ចការនេះ ពុំត្រូវបានអនុវត្តទេ ដោយសារ គ.ផ.ថ ទាំងអស់ បានដឹងច្បាស់អំពីធនធានធម្មជាតិដែលមាននៅក្នុងភូមិ របស់ពួកគេ ។

## ១០.៣ ការវិភាគស្ថានភាពធនធានធម្មជាតិ

តាម NMTM ដែលបានព្រមព្រៀង ការវិភាគស្ថានភាពធនធានធម្មជាតិ ត្រូវបានអនុវត្ត នៅ :

- សកម្មភាព "ខ" នៃជំហានទី១ (បន្ទាប់ពីការកែសំរួលផែនទីឃុំ) ត្រូវបានសំរបសំរួលដោយក្រុម NREM-TFT ។ ការអនុវត្តន៍នៅក្នុងសកម្មភាពនេះ ក្នុងគោលបំណង ដើម្បីពង្រឹងសមត្ថភាព គ.ផ.ថ ផង (ដែលបន្ទាប់មកពួកគាត់នឹងត្រូវធ្វើដូចគ្នានេះនៅក្នុងភូមិរបស់ខ្លួន) និងដើម្បីធ្វើការវិភាគស្ថានភាពធនធានធម្មជាតិនៃឃុំទាំងមូលផង ។ កិច្ចការនេះ ត្រូវការពេលវេលាប្រហែល២ម៉ោង ក្នុងការសំរបសំរួល ។
- សកម្មភាព "ក" នៃ ជំហានទី២ (បន្ទាប់ពីការផ្ទៀងផ្ទាត់ទិន្នន័យភូមិ និងផែនទីឃុំដែលបានកែសំរួល) ត្រូវបានសំរបសំរួលដោយ គ.ផ.ថ នៅក្នុងភូមិរបស់ខ្លួន ។ ក៏ប៉ុន្តែកិច្ចការនេះ ត្រូវបានអនុវត្ត

តែ១ឃុំប៉ុណ្ណោះ (ចំនួន៧ភូមិ) ហើយលទ្ធផលនៃការវិភាគ ប្រហាក់ប្រហែលទៅនឹងលទ្ធផលនៃការវិភាគនៅឃុំ ។ ចំណែកឯឃុំចំនួន៥ផ្សេងទៀត ពុំត្រូវបានអនុវត្តទេ ដោយសារ គ.ផ.ថ បានដឹងច្បាស់អំពីស្ថានភាពធនធានធម្មជាតិដែលមាននៅក្នុងភូមិរបស់ពួកគេ ។

ខាងក្រោមនេះ គឺជាលទ្ធផលនៃការវិភាគស្ថានភាពធនធានធម្មជាតិ

| លរ | ប្រភេទធនធានធម្មជាតិ | ការដាក់ពិន្ទុ | | បញ្ហា/មូលហេតុ | សំណើដំណោះស្រាយ |
|---|---|---|---|---|---|
| | | បច្ចុប្បន្ន | ពីមុន | | |
| ១ | គុណភាពដីកសិកម្ម | ៥ | ៨ | - ការហូរច្រោះ<br>- ដីអស់ជីជាតិ<br>- ដីខះ (ដីក្តាំង)<br>- អស់ព្រៃឈើ<br>- ប្រើជីគីមី | - កែលំអគុណភាពដី ដោយប្រើជីធម្មជាតិ ។<br>- ដាំដើមឈើឡើងវិញ ។ |
| ២ | ព្រៃឈើ និងអនុផលព្រៃឈើ | ៤ | ៩.២០ | - កាប់រានព្រៃធ្វើស្រែ-ចំការ<br>- កាប់អុសដុត<br>- ភ្លើងឆេះព្រៃ<br>- ការកាប់ធ្វើសំណង់ និងលក់ ។<br>- ឈ្មួញកណ្តាល<br>- ឡដុតធ្យូងច្រើន<br>- កំណើនប្រជាជន<br>- កំណើនសិប្បកម្មកែច្នៃអនុផលព្រៃឈើ ដូចជាវល្លិ ល្ពៅ ខ្លឹមច័ន្ទ ។ | - ថែរក្សាការពារព្រៃដែលនៅសល់ ។<br>- ដាំដើមឈើឡើងវិញ ។<br>- បង្កើតសហគមន៍ព្រៃឈើ ឬគ្រប់គ្រងធនធានធម្មជាតិ<br>- លុបបំបាត់ឈ្មួញកណ្តាល ។<br>- ដាំងណាំឧស្សាហកម្ម និងបង្កើតទីផ្សារ ។ |
| ៣ | សត្វព្រៃ | ២ | ៨.៦ | - សង្គ្រាមអូសបន្លាយយូរ<br>- អស់ព្រៃឈើ ឬបាត់ជំរក<br>- ការបបាញ់ និងបំពុល | - ការពារព្រៃឈើ-ដាំបន្ថែម<br>- ផ្សព្វផ្សាយច្បាប់<br>- ហាមបបាញ់ និងបំពុល ។<br>- ការពារសត្វព្រៃ ។ |
| | សត្វព្រៃ (ស្រុកវាលវែង) | ៩ | ៦.៥ | - គ្មានអ្នកបាញ់ ពីព្រោះគ្មានកាំភ្លើង ។ | - បង្កើងសហគមន៍ព្រៃឈើ ។ |

| លរ | ប្រភេទធនធានធម្មជាតិ | ការធ្លាក់ពិន្ទុ | | បញ្ហា/មូលហេតុ | សំណើដំណោះស្រាយ |
|---|---|---|---|---|---|
| | | បច្ចុប្បន្ន | ពីមុន | | |
| ៤ | ព្រៃលិចទឹក | ៩ | ៥ | - កាប់រានព្រៃធ្វើស្រែ-ចំការ ។<br>- ដុតព្រៃរកសត្វ<br>- កំណើនប្រជាជន បណ្តាលអោយតំរូវការអូសដុតកើន | - ទប់ស្កាត់ការដុតបំផ្លាញ ។<br>- ទប់ស្កាត់ការរានព្រៃធ្វើស្រែ-ចំការ ។<br>- បង្កើតសហគមន៍គ្រប់គ្រងធនធានធម្មជាតិ ។ |
| ៥ | មច្ឆាជាតិ | ២.២៥ | ៩.៧៥ | - នេសាទខុសច្បាប់ ។<br>- បាត់បង់ជំរក ដោយសារកាប់បំផ្លាញព្រៃលិចទឹក និងបូមបាចពង្រីងបឹង ។<br>- ភាពរាំងស្ងួតអូសបន្លាយ ។<br>- ប្រើឧបករណ៍ឆក់ និងអ៊ុយយ៉ាំងការ ។<br>- សំរះ ។<br>- សំបូរឡូត៍នេសាទ ។<br>- យកត្រីធ្វើជី ។<br>- កំណើនប្រជាជន ។<br>- ពុលជីគីមី | - ចាត់វិធានការក្នុងការទប់ស្កាត់ការនេសាទខុសច្បាប់<br>- ថែរក្សាការពារព្រៃលិចទឹក និងដាំឡើងវិញ ។<br>- បង្កើតសហគមន៍គ្រប់គ្រងធនធានធម្មជាតិ ។<br>- ចិញ្ចឹមត្រីតាមគ្រួសារ ។<br>- ផ្សព្វផ្សាយច្បាប់ ។<br>- បង្កើតសហគមន៍នេសាទ ។<br>- លុបបំបាត់ឧបករណ៍ខុសច្បាប់ ។ |
| ៦ | ផ្ទៃដីស្រែ | ៩ | ៣ | - កំណើនប្រជាជន ។<br>- ខ្វះដីស្រែ ។ | - កែប្រែគុណភាពដី ។ |
| ៧ | ផ្ទៃដីចំការ | ៧.២៥ | ២.៧៥ | - កំណើនប្រជាជន ។<br>- រានព្រៃធ្វើចំការ ។<br>- ចំការចាស់ដីអស់ជីជាតិ ។ | - មានផែនការបែងចែកអោយបានត្រឹមត្រូវ ។<br>- ដាំដើមឈើឡើងវិញនៅលើចំការចាស់ ។ |
| ៨ | ផ្ទៃទឹក | ៣ | ៨ | - បឹង ស្ទឹង អូរ រីងស្ងួត ក្លាយជាដីស្រែ-ចំការ ។<br>- បរិមាណទឹកភ្លៀងទាប ។<br>- អាកាសធាតុក្តៅខ្លាំង ។ | - ស្តារអូរ បឹង ស្ទឹង ។<br>- ប្រឡាយ ។<br>- ទំនប់ទឹក ។ |

| លរ | ប្រភេទធនធានធម្មជាតិ | ការដាក់ពិន្ទុ | | បញ្ហា/មូលហេតុ | សំណើដំណោះស្រាយ |
|---|---|---|---|---|---|
| | | បច្ចុប្បន្ន | ពីមុន | | |
| | | | | - បាត់បង់ព្រៃឈើ ។ | |
| ៩ | ព្រៃឫស្សី | ៧ | ១០ | - កាប់ធ្វើអាជីវកម្ម ។ | - ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃធនធានធម្មជាតិ ។ |
| ១០ | ថ្ម | ៧ | ១០ | - ធ្វើអាជីវកម្មដោយឈ្មួញ | - លុបបំបាត់អាជីវករ ។<br>- ការពារដោយសហគមន៍ ។ |

**បញ្ហាសំខាន់ៗដែលធាក់ទងទៅនឹងធនធានធម្មជាតិ :**

- ទិន្នផលត្រីចុះទាបយ៉ាងខ្លាំង ។
- ភាពអានាធិបតេយ្យនៃការនេសាទ :
  - ការនេសាទនៅរដូវហាមឃាត់
  - ការប្រើប្រាស់ឧបករណ៍ខុសច្បាប់នានា ដូចជាឧបករណ៍ត្រី មងឬអួនមានក្រឡាញឹកពេក
  - ការនេសាទហួសប្រមាណ ។
- ភាពអានាធិបតេយ្យនៃការកាប់បំផ្លាញព្រៃលិចទឹក :
  - ការកាប់ធ្វើកសិកម្ម ដូចជាដាំសណ្តែក ពោត ស្រូវ ឪឡឹកជាដើម
  - ការកាប់សំរាប់ធ្វើអូស ធ្យូង និងសម្រះត្រី
  - ការកាប់ធ្វើគន្លងនេសាទត្រី
- ភាពអានាធិបតេយ្យនៃការកាប់បំផ្លាញព្រៃឈើ :
  - ការកាប់ធ្វើចំការ និងការកាប់រានចាប់យកដី ។
  - ការកាប់ធ្វើអាជីវកម្មឈើលួចលាក់ ។
  - ការកាប់សំរាប់ធ្វើអូស ធ្យូង និងបង្គោលចម្រឹងឡូតិ៍នេសាទ ។
  - ការកាប់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ។
- ភាពអានាធិបតេយ្យនៃការប្រមូលអនុផលព្រៃឈើ និងសត្វព្រៃ ។

<u>មូលហេតុទាំងអស់ខាងលើនេះ គឺបណ្តាលមកពីភាពមិនច្បាស់លាស់នៃវិសាភាព (ព្រំដែន) និង សិទ្ធិ (ឬកម្មសិទ្ធិ) ក្នុងការគ្រប់គ្រង ។</u>

- ដីខ្សោះជីជាតិ បណ្តាលអោយទិន្នផលស្រូវទាប ។
- ការហូរច្រោះ ។

## ១០.៤ ការកំណត់បញ្ហា/តំរូវការជាអាទិភាព

សំណួរគន្លឹះ បានជួយដល់អ្នកសំរបសំរួល ក្នុងការពង្រឹងសមត្ថភាព គ.ជ.ថ (សកម្មភាព "ឃ" នៃជំហានទី១) និងបានជួយដល់ គ.ជ.ថ ក្នុងការកំណត់បញ្ហា/តំរូវការជាមួយអ្នកភូមិ (សកម្មភាព "ខ១" នៃជំហានទី២) ។

បញ្ហា/តំរូវការជាអាទិភាពដែលទាក់ទងទៅនឹងធនធានធម្មជាតិ (ផ្នែកសេដ្ឋកិច្ច និងផ្នែក NREM) នៅក្នុងឃុំគោលដៅទាំង៦ ត្រូវបានលើកឡើង ។

ឧបសម្ព័ន្ធទី៧ : បញ្ហា/តំរូវការជាអាទិភាពនៃឃុំគោលដៅទាំង៦ (ដកស្រង់ពីផែនការអភិវឌ្ឍន៍ឃុំ) ។

## ១០.៥ ការធ្វើអាទិភាពឃុំគោលដៅទាំង៦ សំរាប់អនុវត្តន៍នៅឆ្នាំ២០០៣

ក្រុម NREM-TFT បានឯកភាពគ្នា ទៅលើលក្ខណៈវិនិច្ឆ័យចំនួន២ ដើម្បីធ្វើអាទិភាពឃុំគោលដៅទាំង៦ សំរាប់អនុវត្តអាទិភាពរបស់ឃុំដែលបានបានលើកឡើង (ឆ្នាំ២០០៣):

- ស្ថានភាពនៃធនធានធម្មជាតិ មានលក្ខណៈស្រួចស្រាវខ្លាំង
- វិវាទ ឬទំនាស់មានសភាពស្រួចស្រាវ ។

លទ្ធផលនៃការធ្វើអាទិភាពឃុំគោលដៅទាំង៦ ដូចខាងក្រោម :

| លំដាប់អាទិភាព | ឃុំ | ស្រុក |
|---|---|---|
| ១ | អន្លាចំបក់ | ក្រគរ |
| ២ | អន្លង់រាប | វាលវែង |
| ៣ | តាលោ | បាកាន |
| ៤ | ប្រម៉ោយ | វាលវែង |
| ៥ | អូរសណ្តាន់ | ក្រគរ |
| ៦ | អូរតាប៉ោង | បាកាន |

## ១១ ការចំនាត់ចំនេចនៅក្នុងបណ្តាញការងារនៃការគ្រប់គ្រងធនធានធម្មជាតិ

- ប្រធានក្រុម NREM-TFT និងតំណាង PLG ពោធិសាត់ បានចូលរួមប្រជុំបណ្តាញការងារសហគមន៍ព្រៃឈើ ដែលត្រូវបានរៀបចំឡើង នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០២ នៅការិយាល័យ អង្គការខុនសឺន ខេត្តពោធិសាត់ ។
- ក្រុម NREM-TFT ចំនួន២នាក់ បានចូលរួមប្រជុំបណ្តាញការងារសហគមន៍ព្រៃឈើអន្តរខេត្ត រយៈពេល ២ថ្ងៃ នៅថ្ងៃទី១១-១២ ខែកញ្ញា ឆ្នាំ២០០២ នៅខេត្តសៀមរាប ។

  ឧបសម្ព័ន្ធទី៨ : របាយការណ៍នៃការប្រជុំបណ្តាញការងារសហគមន៍ព្រៃឈើអន្តរខេត្ត ។

## ១២ ការចូលរួមរបស់គណៈកម្មាធិការប្រតិបត្តិខេត្តពោធិសាត់

គណៈកម្មាធិការប្រតិបត្តិខេត្តពោធិសាត់ បានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគំរោងសាកល្បងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន :

- ធ្វើការពិនិត្យ និងអនុម័តគំរោង ។
- ធ្វើការជ្រើសរើសប្រធានក្រុម និងសមាជិកក្រុម NREM-TFT ។
- ធ្វើការជ្រើសតាំងជនបង្គោល NREM នៃគណៈកម្មាធិការប្រតិបត្តិ ។
- ចេញដីកា សេចក្ដីណែនាំ និងសេចក្ដីសំរេចនានា ។
- ធ្វើការពិនិត្យ និងអនុម័តទៅលើឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាប NREM ។
- ធ្វើទំនាក់ទំនងជាមួយគណៈកម្មាធិការប្រតិបត្តិ និងភ្នាក់ងារអនុវត្តទីគំរោងនានា ។
- ផ្ដល់ការគាំទ្រដល់ដំណើរការនៃការអនុវត្តគំរោងជាប្រចាំ ។

## ១៣ ការចូលរួមរបស់ក្រុមទីប្រឹក្សាធនធានធម្មជាតិ និងបរិស្ថានថ្នាក់ជាតិ និង PLG/STF ភ្នំពេញ

ក្រុមទីប្រឹក្សាធនធានធម្មជាតិ និងបរិស្ថានថ្នាក់ជាតិ គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងគំរោងដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋានភ្នំពេញ បានចូលរួម :

- ទស្សនៈកិច្ចសិក្សាអំពីការគ្រប់គ្រងធនធានធម្មជាតិ នៅខេត្តរតនគីរី ។
- ផ្ដល់យោបល់ក្នុងបង្កើតឧបករណ៍ និងវិធីសាស្ត្របញ្ជ្រាបធនធានធម្មជាតិ និងបរិស្ថាន នៅ៣ថ្ងៃចុងក្រោយនៃការពិភាក្សា ។
- ផ្ដល់មតិយោបល់ទៅលើការចងក្រងបទពិសោធន៍នៃការអនុវត្តគំរោងសាកល្បងបញ្ជ្រាបធនធានធម្មជាតិ និងបរិស្ថាន ។